រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

លេខ: ១៦១៤ ប្រក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
# ស្តីពី
# ការបង្កើតមជ្ឈមណ្ឌលប្រចាំបញ្ជារាជធានីភ្នំពេញ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងសំណូមពរចាំបាច់ នៃការងារ

## ស ម្រេ ច

**ប្រការ១៖** ត្រូវបានបង្កើត "មជ្ឈមណ្ឌលប្រចាំបញ្ជារាជធានីភ្នំពេញ" ស្ថិតក្រោមចំណុះសាលារដ្ឋបាលរាជធានីភ្នំពេញ មានទីតាំងស្ថិតនៅក្នុងបរិវេណសាលារាជធានីភ្នំពេញ។

**ប្រការ២៖** មជ្ឈមណ្ឌលប្រចាំបញ្ជារាជធានីភ្នំពេញ មានតួនាទីជាសេនាធិការជូនគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញ ក្នុងការពិនិត្យតាមដានទិន្នន័យដែលផ្តល់ដោយប្រព័ន្ធកាមេរ៉ា និងទទួលទូរស័ព្ទទាន់ហេតុការណ៍ ដើម្បីបញ្ជាចាត់ចែងដោះស្រាយសភាពការណ៍ដែលកើតមានបន្ទាន់ៗទាក់ទងនឹងសណ្តាប់ធ្នាប់ចរាចរណ៍ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម នៅក្នុងរាជធានីភ្នំពេញ។

**ប្រការ៣៖** ក្រុមប្រចាំបញ្ជា នៃមជ្ឈមណ្ឌលប្រចាំបញ្ជារាជធានីភ្នំពេញមានភារកិច្ច៖

១- តាមដានជាប្រចាំនូវទិន្នន័យរូបភាព ដែលប្រព័ន្ធកាមេរ៉ាបញ្ជូនមកពីទីសាធារណៈ ដើម្បីក្តាប់បានទាន់ពេលវេលាអំពីការកកស្ទះចរាចរណ៍ ការបាត់បង់សណ្តាប់ធ្នាប់សាធារណៈ ឬសកម្មភាពប្រព្រឹត្តបទល្មើសនានា ដែលកើតមាននៅក្នុងរាជធានីភ្នំពេញ។

២- ទទួលទូរស័ព្ទទាន់ហេតុការណ៍ ដែលប្រជាពលរដ្ឋជូនដំណឹង ឬរាយការណ៍អំពីបាតុភាពនានា និងសំណូមពរស្នើសុំអាជ្ញាធរមានសមត្ថកិច្ចជួយអន្តរាគមន៍ ឬសង្គ្រោះ។

៣- ធ្វើការវិភាគជាបន្ទាន់ទិន្នន័យ ឬព័ត៌មានដែលទទួលបាន ដើម្បីបញ្ជាចាត់ចែងដោះស្រាយទាន់ពេលវេលា និងមានប្រសិទ្ធភាព។

៤- បង្កើតសៀវភៅ និងកត់ត្រាទុកនូវរាល់ទិន្នន័យព័ត៌មាន ក៏ដូចជាសភាពការណ៍ដែលកើតឡើងនៅក្នុងវេនប្រចាំបញ្ជារបស់ខ្លួន ត្រូវបូកសរុបរាយការណ៍ប្រចាំថ្ងៃរៀងរាល់ម៉ោង១៥:០០នាទីរសៀលនៃថ្ងៃនីមួយៗ និងបូកសរុបរបាយការណ៍សប្តាហ៍រាយការណ៍ជូនប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញតាមការកំណត់ ដោយត្រូវចម្លងជូនស្នងការនគរបាលរាជធានីភ្នំពេញ និងមេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ០១ច្បាប់ៗ។

៥- រក្សាទុកទិន្នន័យឲ្យបានគត់មត់ និងជួយស្រាវជ្រាវទិន្នន័យព័ត៌មាន ឬសហការស្រាវជ្រាវទិន្នន័យព័ត៌មាននៅក្នុងទិន្នដ្ឋាននៃប្រព័ន្ធ ក្នុងករណីដែលមានតម្រូវការចាំបាច់។

**ប្រការ៤៖** ករណីជនល្មើស ឬមុខសញ្ញាសង្ស័យរត់គេចខ្លួនចេញក្រៅយុត្តាធិការរាជធានីភ្នំពេញទៅកាន់ខេត្តផ្សេងផុតដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រចាំបញ្ជាសាលារាជធានីភ្នំពេញត្រូវផ្តល់ព័ត៌មានមកក្រុមប្រចាំបញ្ជាអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីធ្វើអន្តរាគមន៍ទំនាក់ទំនងជាមួយស្នងការដ្ឋាននគរបាលខេត្តពាក់ព័ន្ធដោះស្រាយឲ្យមានប្រសិទ្ធភាព។

**ប្រការ៥៖** មជ្ឈមណ្ឌលប្រចាំបញ្ជារាជធានីភ្នំពេញ មានក្រុមប្រចាំបញ្ជាចំនួន ០៥ក្រុម ប្តូរវេនគ្នាបំពេញភារកិច្ចជាអចិន្ត្រៃយ៍២៤/២៤ម៉ោង និង០៧ថ្ងៃក្នុង០១សប្តាហ៍ ដើម្បីធានានិរន្តរភាពសកម្មភាព ក្នុងនោះមាន០៤ក្រុម បំពេញភារកិច្ច និង០១ក្រុម សម្រាកប្រចាំរង់ចាំប្តូរវេនវិលជុំ។ វេននីមួយៗមានរយៈពេល ០៦ម៉ោង គឺ៖

-វេនទី១ ចាប់ពីម៉ោង ០៦:០០ ដល់ម៉ោង ១២:០០
-វេនទី២ ចាប់ពីម៉ោង ១២:០០ ដល់ម៉ោង ១៨:០០
-វេនទី៣ ចាប់ពីម៉ោង១៨:០០ ដល់ម៉ោង ២៤:០០
-វេនទី៤ ចាប់ពីម៉ោង ២៤:០០ ដល់ម៉ោង ០៦:០០

**ប្រការ៦៖** ក្រុមប្រចាំបញ្ជានីមួយៗមានមន្ត្រីចំនួន ១៦ នាក់ ដែលមានសមាសភាពមកពីៈ

-សាលារាជធានីភ្នំពេញ ០៣ នាក់ ក្នុងនោះមានអភិបាលរងម្នាក់ ជំនួយការ០១នាក់ និងមន្ត្រីគ្រប់គ្រងប្រព័ន្ធ០១នាក់ ។

-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញចំនួន ១០នាក់ ក្នុងនោះមានស្នងការរង០១នាក់ មន្ត្រីចរាចរណ៍០៧នាក់ និងមន្ត្រីនគរបាលយុត្តិធម៌ ០២នាក់។

-បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញចំនួន ០៣នាក់ ក្នុងនោះមានមេបញ្ជាការរង ០១នាក់ និងមន្ត្រីចំនួន ០២នាក់។

**ប្រការ៧៖** ក្រុមប្រចាំបញ្ជានីមួយៗមាន ឯកឧត្តមអភិបាលរងម្នាក់ជាប្រធាន លោកស្នងការរងម្នាក់ជាអនុប្រធាន មេបញ្ជាការរងកងរាជអាវុធហត្ថម្នាក់ជាអនុប្រធាន មន្ត្រីផ្សេងទៀតជាសមាជិក និងមានមន្ត្រីបច្ចេកទេសចំនួន០១ក្រុម ជាជំនួយការផ្នែកបច្ចេកទេស តាមការចាំបាច់។

ការចាត់តាំង និងបញ្ជីឈ្មោះមន្ត្រីនៃក្រុមប្រចាំបញ្ជានីមួយៗ ត្រូវធ្វើឡើងដោយលិខិត/សេចក្តីសម្រេចរបស់សាលារាជធានីភ្នំពេញ។

**ប្រការ៨៖** ក្រុមប្រចាំបញ្ជាមានសិទ្ធិរាយការណ៍ផ្ទាល់សុំការសម្រេចពីឯកឧត្តម អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញក្នុងការបញ្ជូនបញ្ជា និងប្រើប្រាស់មន្ត្រីនគរបាល នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ មន្ត្រីកងរាជអាវុធហត្ថ នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ និងកម្លាំងសណ្តាប់ធ្នាប់ខណ្ឌ ដើម្បីដោះស្រាយសភាពការណ៍ដែលកើតមានឡើងបន្ទាន់ៗប្រចាំថ្ងៃក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**ប្រការ៩៖** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ សាលារាជធានីភ្នំពេញ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ស្ថាប័ន-អង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ស្ថាប័ន-អង្គភាពពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ៩

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ